# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ចាន់ សៀន ភេទស្រី អាយុ៦០ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ «កងចល័តស្រុក»
## ស្រុកកំណើតនៅភូមិទួលធំ ឃុំត្រឡាច ស្រុកកោះអណ្តែត ខេត្តតាកែវ
## រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ សោម ប៊ុនថន
## ០០:៥២:២៨
## ២៩ទំព័រ

ប៊ុនថនៈ អ្នកមីងឲ្យខ្ញុំថតសម្លេងបន្តិច ដោយសារខ្ញុំកត់ចូលក្នុងសៀវភៅមិនទាន់ មីងនិយាយទៅលឿនពេក ចឹងខ្ញុំសុំអនុញ្ញាតសួរមីង?

សៀនៈ ចាស ។

ប៊ុនថនៈ មីងឈ្មោះអីដែរ?

សៀនៈ ខ្ញុំឈ្មោះ ចាន់ សៀន ។

ប៊ុនថនៈ មីងអាយុប៉ុន្មាន?

សៀនៈ ខ្ញុំចូល៦០ហើយ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅក្នុងភូមិឃុំអីដែរ?

សៀនៈ នៅភូមិស្រុកកោះអណ្តែត ខេត្តតាកែវ ឃុំត្រឡាច ។

ប៊ុនថនៈ ភូមិអីវិញ?

សៀនៈ ភូមិទួលធំ ។

ប៊ុនថនៈ ឃុំត្រឡាច?

សៀនៈ ចាស ។

ប៊ុនថនៈ មីងមានបងប្អូនប៉ុន្មាននាក់ដែរ?

សៀនៈ ខ្ញុំមានបងប្អូន៣នាក់ ។

ប៊ុនថនៈ តែសរុបទាំងអស់ប៉ុន្មាន?

សៀនៈ សរុបស្លាប់អស់ហើយនៅតែ៣នាក់ ។

ប៊ុនថនៈ សរុបទាំងស្លាប់?

សៀនៈ សរុបទាំងស្លាប់បងប្អូនខ្ញុំមាន៨នាក់៥នាក់ហ្នឹង ស្លាប់យូរហើយ ។

ប៊ុនថនៈ ស្លាប់សម័យណា?

សៀនៈ ស្លាប់សម័យមិនទាន់កើតឈឺដោយសារជំងឺ ។

ប៊ុនថនៈ នៅសល់បីនាក់ហ្នឹងរាល់ថ្ងៃគាត់រស់នៅណា?

សៀនៈ រស់នៅស្រុកម្នាក់ទៀតស្លាប់អស់ពីរស្រីមួយប្រុសមួយ រាល់ថ្ងៃហ្នឹងគាត់នៅស្រុកហ្នឹង ។

ប៊ុនថនៈ ចឹងនៅស្រុកពីរនៅសល់បីទាំងមីង?

សៀនៈ ចាស ។

ប៊ុនថនៈ ចឹងឪពុកម្តាយ?

សៀនៈ ឪពុកម្តាយស្លាប់បាត់ហើយ ។

ប៊ុនថនៈ ស្លាប់កាលពីជំនាន់ណាដែរ?

សៀនៈ ស្លាប់ពីសម័យនេះហ្នឹង តែគាត់រស់នៅស្រុកណា ស្លាប់ឆ្នាំ៨៨-៨៩មិនដឹងខ្ញុំមកនេះអត់ដឹងដែរ ។

ប៊ុនថនៈ មីងអត់ដែលទៅលេងស្រុកទេ តាំងពីបែកមក?

សៀនៈ ដែល ។

ប៊ុនថនៈ បានទៅប៉ុន្មានដងដែរ?

សៀនៈ បានទៅញឹកណាស់ ជួនណាមួយឆ្នាំពីរទៅបីដងនោះ ។

ប៊ុនថនៈ ទៅលេងពេលបុណ្យទាន?

សៀនៈ ទៅពេលបុណ្យទានក្អួយការអីហ្នឹង ។

ប៊ុនថនៈ កាលពីក្មេងមីងរៀនសូត្រនៅណាដែរ?

សៀនៈ កាលពីក្មេងអត់មានបានរៀនផងកាលជំនាន់ហ្នឹងអត់បានរៀន ។

ប៊ុនថនៈ ចឹងពេលមីងអត់រៀនចឹងមីងធ្វើអីដែរ?

សៀនៈ ធ្វើស្រែចម្ការរាល់ថ្ងៃ ។

ប៊ុនថនៈ ពេលកាលនៅក្មេង?

សៀនៈ កាលនៅក្មេងខ្ញុំធ្វើស្រែចម្ការនៅស្រុកហ្នឹង ដល់ឆ្នាំ១៩៧៩ហ្នឹងក៏រត់ដោយជាមួយគេមក កាលហ្នឹងគេថាឃួនបុកមកក៏ខ្លាច អត់ដឹងអីដែលកាលហ្នឹង ។

ប៊ុនថនៈ មីងឪពុមម្តាយមីងធ្វើអីកាលហ្នឹង កាលពីក្មេង?

សៀនៈ កាលពីក្មេងម៉ែធ្វើស្រែចម្ការនិងហើយ ឪពុកខ្ញុំគាត់ស្លាប់ចោលខ្ញុំតាំងពីខ្ញុំទើបចេះរៀនដើរ កាលហ្នឹងម៉ែយកប្តីក្រោយទៀតខ្ញុំមិនសូវដឹងថាគាត់ធ្វើអីផង គាត់ស្លាប់ចោលខ្ញុំ ខ្ញុំមិនទាន់ស្គាល់មុនគាត់ច្បាស់ផង ។

ប៊ុនថនៈ ចឹងស្លាប់តាំងពីមីងនៅក្មេង?

សៀនៈ ចាស!តាំងពីនៅតូចទើបចេះដើរ ចេះតែពុម៉ែថា ។

ប៊ុនថនៈ មិនមានបានចូលកងអីទេកាលហ្នឹង កាលពីក្មេងចូលខាងបដិវត្តហ្នឹងមីង?

សៀនៈ កាលចូលបដិវត្តហ្នឹងខ្ញុំចូលមកនេះ ចូលមកខាងកងនារីគេឲ្យធ្វើ ។

ប៊ុនថនៈ ចូលតាំងពីនៅស្រុក?

សៀនៈ អត់ទេ ចេញមកនេះហើយ ។

ប៊ុនថនៈ ចឹងពេលបែករដ្ឋប្រហារអីមីងនៅណាទៅ?

សៀនៈ រដ្ឋប្រហារឆ្នាំ៧៥ ។

ប៊ុនថនៈ រដ្ឋប្រហារឆ្នាំ៧០រដ្ឋប្រហារ លន់ នល់?

សៀនៈ ខ្ញុំនៅផ្ទះ ទើបមករត់យួនហ្នឹង កាលរត់មួយឈុលខ្លាច ។

ប៊ុនថនៈ តែប្រជាជនខ្លាចដែរ?

សៀនៈ កាលហ្នឹងប្រជាជនក៏រត់ ប្រជាជនរត់ដោយតាមគេតាមឯងខ្វះ ចូលមករត់មកនេះ រត់រហូតចូលដល់ដីថៃបានត្រឡប់មកវិញ ។

ប៊ុនថនៈ ចឹងពេលឆ្នាំរដ្ឋប្រហារហ្នឹងមីងនៅស្រុកភូមិទេ?

សៀនៈ ចាស ។

ប៊ុនថនៈ តែមានព្រឹត្តិការណ៍អីទេ ពេលកើតមានរដ្ឋប្រហារហ្នឹង មានជ្រួលច្របល់អីទេ រដ្ឋប្រហារទម្លាក់សម្ដេចហ្នឹង?

សៀនៈ កាលឆ្នាំ៧០ហ្នឹងមានជ្រួលច្របល់តែខាងភូមិខ្ញុំអត់មានអីទេ មានបងខ្ញុំម្នាក់នៅរៀនហ្នឹងកុំគាត់រត់ទាន់កុំអីគេថាខាងណាខាងសម្ដេចខាងណាខាងអីហ្នឹង ដល់ហើយបងខ្ញុំរត់ឡើងផ្ទះចិនរួចបងខ្ញុំរៀនប្រឡងឌីប្លូមនៅព្រៃវែណ្ដក ។

ប៊ុនថនៈ យ៉ាងម៉េចបានគាត់រត់?

សៀនៈ ចុះកាលហ្នឹងគេរកពីណាសីហនុអីហ្នឹង កាលជិនាទ់ហ្នឹង គាត់រត់ផុតបានចិនជួយ កាលហ្នឹងខ្ញុំនៅផ្ទះទេ ខ្ញុំនៅស្រុកទេ បងខ្ញុំនេះគេឈរតម្រៀបនៅព្រៃវែណ្ដក ។

ប៊ុនថនៈ គាត់ខាងសម្ដេច?

សៀនៈ គាត់ខាងមិនដឹងជាស្អីទេ គាត់អ្នករៀនសិស្សសាលាមិនដឹងជាខាងណា រត់បះបោលមួយសារហ្នឹងមិនដឹងជាខាងណាខ្ញុំមិនសូវដឹងដែរ ខ្ញុំនៅស្ទើរដែរ ខ្ញុំនៅស្រុកបើផ្ទះតែម្ដងអត់មានអីទេកាលរដ្ឋប្រហារហ្នឹងនៅព្រៃវែណ្ដក ។

ប៊ុនថនៈ ចឹងកាលហ្នឹងមីងនៅខាងណា នៅខាងលន់ នល់ ឬមួយមីងនៅខាងបដិវត្ត?

សៀនៈ កាលនៅស្រុកនោះនៅខាង លន់ នល់ ខាងស្អីទេ ប្រជាជនមិនទាន់ដឹងទេកាលហ្នឹង ។

ប៊ុនថន៖ ខាង លន់ នល់ ជាអ្នកគ្រប់គ្រង?

សៀន៖ កាលហ្នឹងមិនទាន់រដ្ឋប្រហារដឹងថា សីហនុ ដល់ហើយចូលរដ្ឋប្រហារទៀតដឹងចូលខាងអីខ្ញុំមិនសូវដឹងដែលកាលហ្នឹង មិនទាន់ដឹងច្បាស់ថាខាងណាមិនទាន់ដឹងទេ ។

ប៊ុនថន៖ ចឹងមីងឆ្នាំ១៩៧៥ ពេលខ្មែរក្រហមវាយឈ្នះយកភ្នំពេញបាន ពេលហ្នឹងមីងនៅណាដែរ?

សៀន៖ នៅស្រុកហ្នឹង ខ្ញុំថាទើបមកឆ្នាំ៧៩ហ្នឹងថាយួនយកបាននេះណាយួនដេញនេះណាខ្ញុំរត់មក ។

ប៊ុនថន៖ តែពេលខ្មែរក្រហមវាយយកបានហ្នឹងមីងដឹងដែរ?

សៀន៖ ដឹងតើ ។

ប៊ុនថន៖ ចឹងនៅក្នុងស្រុកភូមិហ្នឹងគេបែងចែកយ៉ាងម៉េចដែរ?

សៀន៖ អត់មានបែងចែកថាអីៗទេ មួយសាររត់ហ្នឹងខ្ញុំមកនេះរហូតមក ខ្ញុំមិនដឹងថាអ្នកស្រុកយ៉ាងម៉េចខ្ញុំមិនសូវដឹង ។

ប៊ុនថន៖ តែមីងគេចាត់តាំងឲ្យធ្វើការអីមីង ឆ្នាំ៧៥ហ្នឹង?

សៀន៖ គេចាត់តាំងហើយអត់ធ្វើអត់នេះអីបងខ្ញុំ ខ្ញុំនៅជាមួយម៉ែ ។

ប៊ុនថន៖ តែថាដូចជាលើកប្រឡាយលើកអី?

សៀន៖ លើកទំនប់ប្រឡាយបានលើកខ្លះដែលហ្នឹង យើងធ្វើដីកដីអីហ្នឹង ។

ប៊ុនថន៖ គេបែងចែកយ៉ាងម៉េច មីងអាចរៀបរាប់បានទេ បងប្អូនមីងឪពុកម្ដាយចាត់តាំងពីធ្វើការ?

សៀន៖ ចាត់តាំងធ្វើការដូចចាស់ៗ ម៉ែឪនៅផ្ទះអីគេឲ្យខាងបេះកប្បាសឲ្យខាងស្អីៗហ្នឹងចាស់ៗណាស់តាមខ្ញុំដឹង ហើយពួកខ្ញុំនេះកាលហ្នឹងនៅកងនារីគេឲ្យធ្វើលើកទំនប់ប្រឡាយអី យើងកូនចៅគេហ្នឹងអី ។

ប៊ុនថន៖ នៅឆ្នាំ៧៥ហ្នឹងមីង?

សៀន៖ ចាស ។

ប៊ុនថន៖ ខាងណាគេចាត់តាំងមីង?

សៀន៖ ខាងភូមិឃុំខាងខ្មែរក្រហមហ្នឹង កាលហ្នឹងគេកាន់អំណាច ។

ប៊ុនថន៖ ចឹងមួយកងមីងមានប៉ុន្មាននាក់?

សៀន៖ មួយកងមួយក្រុម ដូនណាមាន១០នាក់ ។

ប៊ុនថន៖ ចឹងមានពី១០នាក់ទៅ១២នាក់?

សៀន៖ ចាស! ក្រុមពេញមាន១២នាក់ ។

ប៊ុនថន៖ ចឹងប្រធានកងមីងណាវិញ?

សៀន៖ ប្រធានកងស្លាប់បាត់ហើយ ។

ប៊ុនថន៖ មីងកងនារីហ្នឹងនៅក្នុងភូមិទួលធំហ្នឹង?

សៀន៖ នៅដូចថាគេចាត់តាំងលើកប្រឡាយអីៗមានក្រុមមានកងចឹងណាស់ ។

ប៊ុនថន៖ កងនារីស្រុកឬមួយតំបន់មីង?

សៀន៖ កងស្រុក ។

ប៊ុនថន៖ កាលហ្នឹងស្រុកកោះអណ្ដែតហ្នឹងនៅតំបន់ប៉ុន្មានមីង?

សៀន៖ តំបន់ពីដើមមិនដឹងទេ ស្រុកកោះអណ្ដែតហ្នឹង កាលខ្ញុំនៅគេហៅស្រុក១០៨ ហ្នឹងស្រុកជំនាន់ខ្មែរក្រហមយើង ឥឡូវគេហៅស្រុកកោះអណ្ដែត ខេត្តតាកែវ ។

ប៊ុនថន៖ ស្រុក១០៨តំបន់ប៉ុន្មាន?

សៀន៖ តំបន់កាលហ្នឹងតំបន់១៣ចឹងអីតាកែវ ខ្ញុំដូចជាមិនសូវដឹងទេ ដល់ថាស្រុក១០៨ ។

ប៊ុនថន៖ តំបន់១៣ភូមិភាគនិរតី?

សៀន៖ ចាស!ខ្ញុំមិនសូវចាំភ្លេចអស់ ។

ប៊ុនថន៖ ចឹងមីងនៅក្នុងកងនារីស្រុកឬឃុំ?

សៀន៖ នារីស្រុកកាលហ្នឹងដូចជាឃុំអី ឃុំទេ មិនទាន់ដល់ស្រុក ។

ប៊ុនថន៖ ចឹងកាលហ្នឹងគណៈឃុំពីណាគេ?

សៀន៖ គណៈឃុំកាលខ្ញុំនៅហ្នឹងឈ្មោះ បងថា កាលហ្នឹងគេយកទៅណាបាត់អស់ហើយមួយសារហ្នឹងគេដូរអ្នកផ្សេងមក មកថ្មីក្រោយនេះខ្ញុំមិនសូវដឹង ។

ប៊ុនថន៖ មុនឈ្មោះ ថា?

សៀន៖ ហ្នឹងហើយ ។

ប៊ុនថន៖ ចឹងគណៈស្រុកពីណាគេ?

សៀន៖ គណៈស្រុកផ្លាស់ថ្មីទៀតខ្ញុំមិនសូវដឹងដែរ កាលជំនាន់ខ្ញុំនៅឥឡូវគាត់ស្លាប់បាត់ហើយកាលហ្នឹងស្រុក១០៨ កាលដើមឡើយសម័យហ្នឹង មេស្រុកឈ្មោះ កែវ ឥឡូវគាត់ស្លាប់តាំងពីសម័យនោះ ។

ប៊ុនថន៖ កែប?

សៀន៖ មេស្រុក កែវ នៅតែកូនធ្វើការនៅភ្នំពេញ ហើយក្រោយទៀតខ្ញុំអត់ដឹងទេ ។

ប៊ុនថន៖ ចុះតំបន់មីង គណៈតំបន់១៣?

សៀន៖ គណៈតំបន់១៣កាលហ្នឹង ពីណាទេ ស្លាប់អស់ហើយពីណា តាសុច ខ្ញុំដឹងជំនាន់ខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

សៀនៈ តាសុច តាសឿន តាណាទៀតទេ ខ្ញុំភ្លេចអស់ហើយ តែសុទ្ធតែស្លាប់អស់ហើយ ខ្ញុំមិនសូវចាំអស់ អើមាន តាមុត អីហ្នឹង ។

ប៊ុនថនៈ តាមុត?

សៀនៈ តាមុត ស្លាប់ហើយដឹងខ្ញុំមកនេះយូរហើយ ខ្ញុំចាំវាមិនអស់ ។

ប៊ុនថនៈ មីងនៅកងនារីឃុំហ្នឹងធ្វើអីខ្លះទៅ?

សៀនៈ ខ្ញុំធ្វើខាងឃុំនេះហ្នឹងមានអី ខ្ញុំនៅក្រោមគេដែលហ្នឹង ខ្ញុំនៅកូនក្រុមគេដែលហ្នឹង ធ្វើការកាលហ្នឹងមានលើកប្រឡាយអីហ្នឹង ។

ប៊ុនថនៈ ចុះក្រោយមកមីងមានផ្លូទៅខាងណាទៀតទេ?

សៀនៈ ខ្ញុំនារីឃុំខ្ញុំចូលមកខាងនេះ ។

ប៊ុនថនៈ ចូលមកខាងណាវិញ?

សៀនៈ ចូលមកខាងខ្មែរក្រហមយើងនេះ ។

ប៊ុនថនៈ ចឹងមីងធ្វើពី៧៥រហូត មីងធ្វើអត់មានផ្លូទេ ដល់៧៩បានរត់មក?

សៀនៈ ខ្ញុំរត់មក រត់តាំងពីមកហ្នឹងរត់ហ្នឹង អត់មានផ្លូផ្លាស់ទៅស្រុកអីអត់មានទេ គេអត់មានឲ្យទៅ ។

ប៊ុនថនៈ អត់មានទៅកងនារីស្រុកតំបន់អីទេ?

សៀនៈ អត់ទេ ។

ប៊ុនថនៈ ចឹងនៅហ្នឹងរហូតដល់បីឆ្នាំពី៧៥ដល់៧៩?

សៀនៈ នៅរហូតតែម្តង អត់មានផ្លាស់ផ្លូទៅណាទេ ចង់ទៅណាចង់ទៅស្រុកគេមិនឲ្យទៅខ្ញុំផ្តាច់ខ្លួនក្រោយរដ្ឋប្រហារ អះ!ក្រោយសមាហរណ៍កម្មហើយបានទៅលេងស្រុកបាន ។

ប៊ុនថនៈ ចឹងមីងអាចរៀបរាប់ទេ ពេលមីងរត់ពីឆ្នាំ១៩៧៩មកនៅនេះ ដំបូងមីងទៅណាវិញរត់ពីខេត្តតាកែវ?

សៀនៈ ខ្ញុំរត់ពីណឹងមកយើង ខ្ញុំរត់ទៅរតនគិរីដល់ហើយ៧៩រត់មកចឹងដល់ហើយរត់ឡើងភ្នំទៅរត់ពីរតនគិរីមករហូត ។

ប៊ុនថនៈ យ៉ាងម៉េចបានជារត់ទៅរតនគិរីវិញ?

សៀនៈ ចុះបើគេចេះតែនាំៗទៅចេះតែទៅ ។

ប៊ុនថនៈ មីងយួនមិនវាយមកពីកើតវិញ?

សៀនៈ មកពីខាងកើតហ្នឹង ដូចថាយើងទៅដូចថាកាលហ្នឹងគេចាត់តាំងទៅអីហើយទទួលយួនដេញមកក៏រត់ឡើងភ្នំរតនគិរីទៅ ។

ប៊ុនថនៈ ចឹងគេចាត់តាំងឲ្យទៅរត់រតនគិរី?

សៀន៖ ហ្នឹងហើយគេឲ្យទៅការឲ្យធ្វើប្រជាជន ចេះតែឲ្យទៅយើងមានដឹងអីចេះតែទៅ ។

ប៊ុនថន៖ ឆ្នាំប៉ុន្មានគេចាត់តាំងពីឲ្យទៅរតនគិរីហ្នឹង?

សៀន៖ ឆ្នាំហ្នឹងគ្រាន់ទៅដល់យួនចូល ចុងឆ្នាំ៧៨ដឹង ទៅដល់ទទួលគេថា យួនចូលមកហ្នឹងណារត់ឡើងភ្នំបណ្តោយ កាលហ្នឹងចេះតែខ្លាចយួនចាប់ ។

ប៊ុនថន៖ កាលហ្នឹងពីណាចាត់តាំងមីង?

សៀន៖ កាលហ្នឹងអ្នកចាត់តាំងហ្នឹងផ្នែកខាងទ័ពគេយកទៅ ។

ប៊ុនថន៖ កងទ័ពហ្នឹងកងទ័ពតំបន់ឬកងទ័ពស្រុកគឺខាងណា?

សៀន៖ ខាងភូមិភាគនិរតីហ្នឹង តែឥឡូវគាត់ស្លាប់បាត់ហើយ ។

ប៊ុនថន៖ ឈ្មោះអីវិញ?

សៀន៖ តា០៥ ។

ប៊ុនថន៖ ០៥គាត់នៅកងពល?

សៀន៖ កងពល៨០១ ដោយសារប្រពន្ធទ័ពគាត់យកទៅណាស់ យើងមានគូរដណ្តឹងអីចឹងក៏គេហៅទៅដែលទៅណាស់ ចឹងដោយៗតាមគេទៅ មានគូរដណ្តឹងគេហៅទៅ ។

ប៊ុនថន៖ កាលហ្នឹងគាត់ថាឲ្យទៅរតនគិរីធ្វើអីវិញ?

សៀន៖ ទៅតាមគ្រួសារ គូរដណ្តឹងគេហៅទៅហ្នឹងគេជិតជ្រើសរើសអ្នកមានគូរដណ្តឹងមានអីគេចុះស្រាវជ្រាវរកតាមភូមិឃុំគេហៅទៅ ។

ប៊ុនថន៖ ចឹងគ្រួសារមីងកងទ័ព?

សៀន៖ ចាស ។

ប៊ុនថន៖ គាត់កងទ័ពវិញមីង កាលហ្នឹង?

សៀន៖ កាលហ្នឹងនៅភូមិគេហ្នឹង៨០១ហ្នឹងហើយ គេហៅតាមគ្រួសារទៅក៏ទៅ ។

ប៊ុនថន៖ គាត់មានឈ្មោះអីដែរ?

សៀន៖ ស្លាប់អស់ហើយ ។

ប៊ុនថន៖ គ្រួសារមីង?

សៀន៖ ឈ្មោះ ជិន ស្លាប់បាត់ ។

ប៊ុនថន៖ កាលហ្នឹងគាត់ឈ្មោះ ស្អី ជិន?

សៀន៖ ឈ្មោះ ជ័យ ជិន ។

ប៊ុនថន៖ គាត់នៅរស់ទេ?

សៀន៖ អត់ទេ បែកគ្នាមិនដឹងជាគាត់ទៅណា រដ្ឋប្រហារក៏បែកគ្នាទៅ ខ្ញុំនៅតែឯងបែកគ្នាមិនដឹងជាគាត់ទៅខាងណាខាងណី ។

ប៊ុនថន៖ គាត់មានតួនាទីអីដែរ?

សៀន៖ អត់មានតួនាទីអីទេ កាលហ្នឹងកូនចៅគេ ។

ប៊ុនថន៖ គាត់នៅ៨០១ជាមួយតាសួរ សារឿន ហ្នឹង?

សៀន៖ កងនេះគេ តែកាលហ្នឹងរត់បែកគ្នាទៅយួនដេញ ។

ប៊ុនថន៖ មីងការជាមួយគាត់ឆ្នាំណា?

សៀន៖ ខ្ញុំរៀបការជាមួយគាត់ហើយ យួនដេញហ្នឹងឆ្នាំ៧៩ហ្នឹង ។

ប៊ុនថន៖ មីងរៀបការជាមួយគាត់មុនទៅរតនគិរីឬទៅដល់រតនគិរីបានរៀប?

សៀន៖ ដល់រតនគិរីគេហៅទៅ ។

ប៊ុនថន៖ ចឹងពីមុនហ្នឹងគូដណ្ដឹងទេ?

សៀន៖ ពីមុនគូដណ្ដឹងវាមិនបានកូនចៅវាត្រឹមគូដណ្ដឹង ដល់ហើយគេជ្រើសរើសយកទៅណាស់អ្នកមានកូនមានប្ដីនៅហ្នឹង អ្នកណាជិវិតនៅគេជ្រាវយកទៅ ហើយគាត់រៀបហើយគាត់បែកគ្នាមិនដឹងជាគាត់រត់ទៅខាងណា ។

ប៊ុនថន៖ តែមីងនៅជាមួយគាត់មុនទៅរតនគិរី?

សៀន៖ ចាស! នៅជាមួយគ្នាហ្នឹង គាត់នៅទ័ពអត់មានកូនចៅដល់ហើយ គាត់ចេញមកដល់រដ្ឋប្រហារហ្នឹងក៏៧៩ហ្នឹងរត់បែកគ្នា មិនដឹងជាគាត់ទៅណាមកណា ។

ប៊ុនថន៖ ចឹងមីងទៅរតនគិរីហ្នឹងមិនបាននៅជាមួយគាត់ទេ?

សៀន៖ នៅតើ ដល់ហើយយួនដេញហ្នឹង រត់បែកគ្នា បែកគ្នាក៏បាត់រហូតមិនដឹងជាទៅខាងណា ។

ប៊ុនថន៖ មីងមានដឹងថា គាត់នៅវរះណាទេ?

សៀន៖ អត់ដឹង ។

ប៊ុនថន៖ មីងទៅហ្នឹង មីងទៅជាមួយកូនតែម្ដង?

សៀន៖ ចាស ។

ប៊ុនថន៖ ទៅហ្នឹងគាត់មានថាម៉េចដែរ ពេលទៅរតនគិរីហ្នឹង?

សៀន៖ អត់ទេ មានថាអី ។

ប៊ុនថន៖ គេថាឲ្យទៅរស់នៅហ្នឹង?

សៀន៖ ហ្នឹងហើយ ឲ្យទៅហ្នឹងឲ្យទៅមូលកូនមូលប្រពន្ធប្ដីវិញ កាលនេះយើងនៅស្រុកនៅផ្ទះហ្នឹង ។

ប៊ុនថន៖ មីងទៅដល់រតនគិរីដំបូង មីងនៅណា នៅម្តុំណា?

សៀនៈ ខ្ញុំនៅមុនដំបូងខ្ញុំនៅរីនសៃ ។

ប៊ុនថនៈ ទៅនៅទីរួមស្រុករីនសៃតែម្តង?

សៀនៈ ចាស ។

ប៊ុនថនៈ គ្រួសារមីងនៅរីនសៃដែរ?

សៀនៈ ស្រុកកំណើតគាត់ ។

ប៊ុនថនៈ គាត់នៅជាមួយមីងនៅរីនសៃដែរ?

សៀនៈ ខ្ញុំទៅដល់ហ្នឹងហើយបានគេឲ្យទៅតាមនៅអី អូរដំបូកលើ ។

ប៊ុនថនៈ ចឹងប្តីមីងនៅអូរដំបូកលើ?

សៀនៈ ចាស ។

ប៊ុនថនៈ អូរដំបូកលើនៅស្រុកអីវិញមីង រីនសៃដែរ?

សៀនៈ រីនសៃដែលក៏អីទេ ខ្ញុំមិនសូវស្គាល់ផង ។

ប៊ុនថនៈ អូរដំបូកលើហ្នឹងនៅជាប់ខាងព្រំប្រទល់អីមីង?

សៀនៈ អូរដំបូកលើនៅខាងស្អីខាងមាត់ទន្លេដែរ ខាងលើសៀមប៉ាងទៀត ។

ប៊ុនថនៈ ជាប់ខាងឡាវទេ?

សៀនៈ ជាប់ខាងឡាវ មួយដូរហ្នឹងតែមិនដល់ឡាវពេកទេ នៅជាប់ទន្លេហ្នឹងនៅម្តុំភូមិប៊ុនពុង រីនសៃហ្នឹងភូមិប៊ុនពុង តែគាត់នៅកន្លែងស្អីទេ កន្លែងហ្នឹងនោះ មាត់ទន្លេគេហៅភូមិអីទេ ខ្ញុំភ្លេចអស់ហើយ ។

ប៊ុនថនៈ មីងនៅអូរដំបូងលើហ្នឹងបានរយៈពេលប៉ុន្មានខែមីង?

សៀនៈ នៅបានប៉ុន្មានខែទេ នៅបានពីរខែ ហើយរត់យួន ។

ប៊ុនថនៈ ចឹងមីងនៅហ្នឹងធ្វើអី?

សៀនៈ ខ្ញុំនៅហ្នឹងអត់មានធ្វើអីទេ ប្រពន្ធកងទ័ពមានធ្វើអីផង ។

ប៊ុនថនៈ ចឹងនៅផ្ទះ?

សៀនៈ ចាស! នៅផ្ទះគេឲ្យធ្វើស្រែចម្ការដែលហ្នឹង ។

ប៊ុនថនៈ ចឹងប្តីមីងនៅហ្នឹងដែរ?

សៀនៈ ចាស ។

ប៊ុនថនៈ ចឹងពេលវាយមកហ្នឹងមីងរត់ទៅជួបជាមួយប្តី?

សៀនៈ ចាស! រត់ជុំគ្នា នៅវាយជាមួយគ្នាហ្នឹង ។

ប៊ុនថនៈ កាលហ្នឹងមានកូនប៉ុន្មាននាក់ហើយមីង?

សឿន:   ខ្ញុំកាលហ្នឹងពោះធំមានកូនពីរនាក់ ។

ប៊ុនថន:   វត់ទៅណាវិញ?

សឿន:   វត់មកដល់នេះទៀត វត់មកឡើងភ្នំរតនគិរីហ្នឹង ឡើងភ្នំរហូតបានមកព្រំដែនថៃមកខាងទន្លេល្មៅៗនោះ ។

ប៊ុនថន:   មិនមែនទៅខាងមុំបីទេ?

សឿន:   មកខាងហ្នឹងឯងមុំបីហ្នឹង ទន្លេល្មៅនោះ ឡាវព្រំដែនឡាវហ្នឹងមករហូតដល់ព្រំដែនថៃនេះទន្លេល្មៅមុំបីហ្នឹង នៅជ្រុងខាងជើងទន្លេល្មៅហ្នឹង ។

ប៊ុនថន:   វត់ទៅច្រើនទេ?

សឿន:   ច្រើនទៅទាំងអស់ហ្នឹង យួនដេញហ្នឹងនៅភាគតិចណាស់ វត់បន្តគ្នាខ្លះត្រូវមីនស្លាប់ទៅខ្លះរស់វត់ទៀតទៅ ។

ប៊ុនថន:   ចឹងមានអ្នកអត់វត់ទេ?

សឿន:   អ្នកគេទ័ពគេនៅហ្នឹង បើយើងដូចថាគេឯត់មានកូនចៅយើងទៅមូលប្ដីយើងទៅវត់ទៅចូលដីថៃបើចឹងកូនចៅបានពីណាជួយយក ។

ប៊ុនថន:   វត់ឆ្លងទន្លេមីង?

សឿន:   វត់ហ្នឹងអត់ទេ វត់ឡើងភ្នំ ចុះអូរឆ្លងអូរហ្នឹង ឆ្លងជ្រោះអីចឹងណាស់ ឡើងភ្នំខ្ពស់ចឹងអីទៅឡើងចុះទៅវិញចុះឡើងតាមអូរធំៗហ្នឹងទៅ ដល់ទៅថៃលែងអីហើយដល់ដីថៃ ។

ប៊ុនថន:   មានស្លាប់អីតាមផ្លូវទេ?

សឿន:   មាន ជួនណាបាញ់ប្រាវទៅវាយគ្នាទៅ បាញ់ប្រាវទៅត្រូវទៅហើយជួនណាអ្នកមិនដឹងដើរទៅជាន់មីនផ្ទុះងាប់កូនចៅទៅអ្នកទៅជាមួយហ្នឹងត្រូវទៅអ្នកណានេះទៅទៀតទៅមិនបានជួយយកពីណាអត់ទេ ។

ប៊ុនថន:   បាទ ។

សឿន:   វត់យករួចខ្លួនពេលហ្នឹង កាំភ្លើងបាញ់ពីក្រោយអា១០៥ផ្លោងវត់រហូត ។

ប៊ុនថន:   ខាងណាបាញ់?

សឿន:   ខាងនេះដេញទៅ ដេញទៅហ្នឹងខាងនេះទប់ទៅ គេវាយទៅគេដកខ្លួនដែរ ដល់ហើយខាងយួននេះផ្លោងដែរ ជួនណាពីណាចំក៏ចំទៅអ្នកណារស់វត់ទៀតទៅ ។

ប៊ុនថន:   ចឹងវត់ចឹងមានស្បៀងអីដែលមីង?

សៀនៈ   មានតើ  អ្នកណានេះចោលទៅ  ចោលអីវ៉ាន់អស់ទៅ  យើងមានយកទៅដូចថា  អើវាឆាប់ដែលមួយយប់មួយថ្ងៃបានចូលដីថៃដែរ  ពួកកាកបាទគេមកជួយណា  គេដឹកឥវ៉ាន់មកជួយយើងបានហូប ។

ប៊ុនថនៈ   មីងរត់ប៉ុន្មានថ្ងៃពីកន្លែងមីងនៅអូរដំបូកលើហ្នឹង ពីទន្លេល្ពៅ?

សៀនៈ   បើគិតពីនោះមកសឹករាប់ខែដែលហ្នឹង យើងរត់ពីរតនគិរីមកឆ្លងទន្លេសេកុង ទន្លេសេសាន ។

ប៊ុនថនៈ   បាទ ។

សៀនៈ   មកពីនោះមកឆ្លងទន្លេពីរហ្នឹង ។

ប៊ុនថនៈ   ហើយបានមកដល់ទន្លេល្ពៅ?

សៀនៈ   ចាស!មកទន្លេល្ពៅ ទន្លេល្ពៅអូរទេ តែគេហៅទន្លេល្ពៅ ។

ប៊ុនថនៈ   បាទ ។

សៀនៈ   ហើយយួនដេញមកទៀត រត់បាមឡើងភ្នំចុះភ្នំបានចូលដីថៃ ។

ប៊ុនថនៈ   ចឹងពីរតនគិរីមកដល់ទន្លេល្ពៅហ្នឹងយូរទេ?

សៀនៈ   យូរដែលទំរាំបានចេញមករួច  នៅក្នុងព្រៃភ្នំកាលហ្នឹងប្រហែលជាមួយឆ្នាំជាងដឹង  រស់នៅក្នុងភ្នំដូចសត្វចឹងណាស់ ។

ប៊ុនថនៈ   ដល់ឆ្នាំ៨០មីង?

សៀនៈ   ហ្នឹងហើយដល់ហ្នឹងបានខ្ញុំមកបានចេញរួចហ្នឹង     យួនស្កាត់ផ្លូវហ្នឹងចាំវាយផ្លូវស្កាត់ផ្លូវពីណាស្លាប់ៗទៅពីណារស់ឆ្លងទន្លេទឹករសាត់ទៅក្រោមទៅខ្លះអោបគល់រាំងទៅខ្លះលិចទឹកស្លាប់ទៅ ។

ប៊ុនថនៈ   មីងអាចរៀបរាប់បានទេ នៅក្នុងព្រៃរយៈពេលមួយឆ្នាំហ្នឹងបានអីហូបទៅមីង?

សៀនៈ   ហូបដំឡូងហូបក្តួច អត់មានអីហូបអំបិលក៏អត់មានដែរ ។

ប៊ុនថនៈ   ចឹងយ៉ាងម៉េចដែលមីង?

សៀនៈ   ចុះធ្វើម៉េចបើយើងមិនដឹងជាចេញមកផ្លូវណារួច   ដល់យើងនៅយូរបានមានរយៈទាក់ទងមកឆ្លងទន្លេមក  ទៅខែទឹកឡើងខ្លះរសាត់ទៅក្រោមខ្លះក៏ស្លាប់ទៅ  ខ្លះរត់រួចទៅឆ្លងគេត្រៀមវាយតាមផ្លូវទៅ អ្នកណារត់រួចក៏រួចទៅអ្នកណាងាប់ក៏ងាប់ទៅ ។

ប៊ុនថនៈ   នៅច្រើនទេ ដែលថានៅក្នុងព្រៃហ្នឹង?

សៀនៈ   ច្រើនតើ នៅតាមកងតាមអីនៅគ្រប់កន្លែងហ្នឹង នៅកន្លែងយួនវាយរាល់ថ្ងៃហ្នឹង បើយួនចាប់បានអត់មានអីទេ ខូចតែវាយគ្នាត្រូវគ្រាប់ ។

ប៊ុនថនៈ   ចឹងមានគេចាប់បានទេ?

សៀន: មានគេ ចាប់បានយកទៅដាក់កោះកន្ទុយគោ តែអត់មានសាប់ទេ ឲ្យតែយួនចាប់បានខ្លាចតែកំពង់វាយគ្នាត្រូវគ្រាប់ទេ ។

ប៊ុនថន: ចឹងមានអ្នករត់ចូលទៅខាងយួនទេ?

សៀន: ទេ កាលមួយសារហ្នឹងខ្ញុំចេញមក មានគេ កាលហ្នឹងមានអ្នកខ្លះគេទៅសារភាពណារួចខ្លួនទៅ វាពិបាកពេកណាស់ ។

ប៊ុនថន: បាទ ។

សៀន: អ្នកណាដាច់ខាតមិនដាច់ខាតខ្លាច អ្នកខ្លះមានបាតុភាពអី មានទំនាស់អីវាខឹងរត់ទៅណាស់វាសុខចិត្តថានេះក៏ពិបាក បើគេដាច់ខាតគេចូលទៅ រយៈគេមានគេចូលទៅមិនអីទេ យើងអត់មានរយៈហ្នឹងខ្លាចដែរ ។

ប៊ុនថន: ចឹងគេមានរយៈទាក់ទងគ្នា?

សៀន: ចាស!ខ្លះគេមានផ្ទៃក្នុងគេ រយៈទាក់ទងទៅរួចខ្លួនទៅ អាគ្នាមិនដឹងវាយទៅចាប់បានទៅអត់មានអីទេ តែដាប់គុកយួន ពួកកងនារីពួកខ្ញុំខ្លះ យួនចាប់បានយកសួរចម្លើយដែលតែមិនដាប់គុកយូរទេ គេបញ្ជូនទៅតាមភូមិឃុំ ស្រុកនៅណាគេបញ្ជូនទៅស្រុកហ្នឹង ហ្នឹងយួនចាប់បានកុំឲ្យតែយើងវាយគ្នាត្រូវ បើយើងមានរបួសក៏គេយកទៅព្យាបាលដែរ ។

ប៊ុនថន: បាទ!ចឹងមីងរត់នៅក្នុងព្រៃហ្នឹងជុំជាមួយប្ដីមីងដែរ?

សៀន: ជុំ ។

ប៊ុនថន: ចឹងជាមួយកូនពីរនាក់?

សៀន: ចាស!កូនពីរនាក់មួយពោះធំ ។

ប៊ុនថន: ចឹងនៅក្នុងព្រៃហ្នឹងសង់ជាផ្ទះឬមួយយ៉ាងម៉េចដែរ?

សៀន: អត់ទេ នៅចងដេកព្រៃភ្នំហ្នឹងមានពីណាមានកៅស៊ូអីចងពីលើមក អត់មានចងក្រោមដើមឈើព្រៃលើភ្នំហ្នឹងទៅ ដូចសត្វចឹង ។

ប៊ុនថន: ចឹងខាងវៀតណាមអីអត់មានរកឃើញទេ?

សៀន: អត់ទេ បើឡើងទៅវាឃើញស្លាត់ផ្លូវដែលហ្នឹង យើងរត់អីហ្នឹងគេឃើញគេបាញ់ទៅយើងរត់ទៅបើត្រូវក៏ស្លាប់បើត្រូវរបួសក៏របួសពីណានេះ រត់រួចទៅមានបែកគ្នាទៀត ខ្លះបែកគ្នានៅម្នាក់ឯងពីរនាក់ ស្លាប់ក្នុងព្រៃក៏មានរតនគិរី ។

ប៊ុនថន: បាទ ។

សៀន: យួនឃើញបាញ់ យើងនៅតាមព្រៃដុំគ្នាទៅយួនវាយរត់ចោលឆ្នាំងចានចឹងទៅអ្នកណាត្រូវរបួសក៏ត្រូវទៅអ្នកណាស្លាប់ក៏ស្លាប់ទៅចោលឆ្អឹងហ្នឹងទៅ ។

ប៊ុនថន៖ ចុះអង្ករអត់មានអង្ករអត់មានអី?

សៀន៖ អង្ករមកភូមិក៏បានទៅបើអត់ហូបតែដំឡូងទៅ ដំឡូងសម្បូរកាលហ្នឹង ។

ប៊ុនថន៖ ចឹងមីងបានអីឆ្លងមកខាងទន្លេល្ពៅនេះ?

សៀន៖ កាប់ឫស្សីធ្វើក្បូនហ្នឹង កាប់ឫស្សីចងវាមុខវារៀងស្រួចទៅយើងកាន់ឆ្លងមក អ្នកណានេះគេមេគេអ្នកនេះក៏គេបានទូកដួលទូកប្រជាជនមកពួកខ្ញុំឆ្លងឫស្សីចងឫស្សីជាក្បូនឆ្លងទៅ ។

ប៊ុនថន៖ ច្រើនាក់ទេ?

សៀន៖ ច្រើន ឡើងប៉ុន្មានរយនាក់នោះ ឡើងមកហ្នឹងយួនវាយរត់បែកគ្នាទៅ ឆ្លងមេកុងសេសានពួកហ្នឹងឆ្លងតាមហ្នឹងឯង ។

ប៊ុនថន៖ ឆ្លងពេលថ្ងៃឬពេលយប់?

សៀន៖ ឆ្លងយប់មួយថ្ងៃល្ងាច អ្នកណានេះគេឆ្លងថ្ងៃ ឆ្លងច្រើនគ្នាណាស់មួយសារ១ៗអ្នកណាឆ្លងមកទឹកឡើងមកទឹកគួចទៅក្រោមទៅជាប់គល់រាំងប្រជាជនឬយួនហ្នឹងដោលទូកមកយកទៅស្រុកទៅភូមិទៅយួនចាប់បានគេមានធម៌ដែលកាលហ្នឹង គេបញ្ជូនទៅស្រុក ។

ប៊ុនថន៖ ឆ្លងមកខាងទន្លេល្ពៅហើយមីងទៅខាងណាទៀត?

សៀន៖ មកខាងថៃ រត់ហ្នឹងហើយយួនវាយទៅទន្លេល្ពៅបានរត់ទៅថៃ រត់ទៅព្រំដែនថៃទៅនៅជាមួយថៃរហូត ។

ប៊ុនថន៖ នៅម្តុំណា គេហៅអីវិញ?

សៀន៖ នៅម្តុំដងទង់ ។

ប៊ុនថន៖ ចឹងចេញពីទន្លេល្ពៅហ្នឹងមកខាងដងទង់?

សៀន៖ ចាស!មកនៅតាមវាយស្រែគេហើយចឹង គេយកទៅរហូតមកដល់ភ្នំ ។

ប៊ុនថន៖ ដងទង់ ចងកអីហ្នឹង?

សៀន៖ ហ្នឹងហើយម្តុំចងកហ្នឹង ។

ប៊ុនថន៖ អាហ្នឹងចូលទៅក្នុង១០០១-១០០២ឬ១០០៣?

សៀន៖ ១០០១ហ្នឹងចូលក្នុង១០០៣កន្លែងណឹងអី ។

ប៊ុនថន៖ ដងទង់ហ្នឹង១០០៣?

សៀន៖ ចាស!ដូចជា១០០៣កន្លែងហ្នឹង នៅដងទង់អូរចងកហ្នឹង អូរត្រាវហ្នឹង ។

ប៊ុនថន៖ បាទ ។

សៀន៖ តែពួកខ្ញុំមិនបាននៅអូរត្រាវទេ ។

ប៊ុនថន៖ គ្រួសារមីងមានមកជាមួយទេ?

សៀន: មកជាមួយជាមួយគាត់ ។

ប៊ុនថន: មកនៅខាងជងទន់ហ្នឹង?

សៀន: ចាស ។

ប៊ុនថន: ចឹងកាលនៅជងទន់គេរៀបចំយ៉ាងម៉េចទៅ?

សៀន: នៅជាប្រជាជនហ្នឹងដូចថា រៀបប្រជាជនហ្នឹង គេរៀបតាមភូមិតាមកងគេចឹងទៅណាស់ គេបើមកចែកអីឲ្យហូបទៅណាស់ ខាងកាកបាទគេដឹកមកចឹងគេចែកឲ្យហូបទៅ តែចូលដល់ហ្នឹងលែងងាប់ហើយ ។

ប៊ុនថន: ចឹងកាលហ្នឹងខាងកាកបាទអ្នកគ្រប់គ្រង?

សៀន: ខាងកាកបាទគេឲ្យជំនួយតាមរយៈហ្នឹងមក ចូលកន្លែងដីថៃឃ្លាំងគេធ្វើចឹងទៅគេចែក ។

ប៊ុនថន: គេចែករបបក្នុងមួយនាក់ប៉ុន្មានដែលពេលហ្នឹង?

សៀន: ម្នាក់កាលហ្នឹងមានទាំងត្រីខ ទាំងមី អ្នកណាកូនច្រើនទៅបានច្រើនទៅ អ្នកណាកូនតិចបានតិច អ្នកណាកូនច្រើនបានចង់មួយឡាំងចឹងទៅ កូនតិចបាន៥ទៅ៦កញ្ចប់ចឹងទៅ អ្នកអត់មានកូនបានត្រឹមបីទៅបួនអីទៅ ។

ប៊ុនថន: មីហ្នឹង?

សៀន: ចាស!មីហ្នឹង គេឲ្យតាមមនុស្ស ។

ប៊ុនថន: ប៉ុន្មានថ្ងៃគេចែកម្តង?

សៀន: ដូនណាញឹកញាប់ដែលហ្នឹង ដូនណាបីបីថ្ងៃទៅ គេចែកអង្ករចែកអី ដូនណា១០ថ្ងៃដូនណា៥ថ្ងៃវាមិនទៀងទេ ។

ប៊ុនថន: នៅចឹងកហ្នឹងពីណាគ្រប់គ្រងនៅហ្នឹងមីង នៅខាងជងទន់ហ្នឹង?

សៀន: គ្រប់គ្រង ។

ប៊ុនថន: នៅជំរំហ្នឹង?

សៀន: នៅជំរំហ្នឹង កាលហ្នឹងមានតាអីទេ ខ្ញុំមិនដែលបានឃើញមិនដែលស្គាល់ទេ តាខៀវ តាអីទេកាលហ្នឹង ។

ប៊ុនថន: តាខៀវ ហៅសុន សេន ហ្នឹង?

សៀន: ហ្នឹងហើយ ខ្ញុំមិនដែលឃើញមុខមាត់គាត់ទេ មិនដែលឃើញទេ យើងជាប្រជាជន គាត់ដូចថាក្តាប់រួមតាមរយៈគេដឹកស្បៀងឲ្យមក តាមរយៈហ្នឹងទៅ គេដឹកយកមកឲ្យប្រជាជន ។

ប៊ុនថន: ចឹងមីងឆ្នាំ១៩៨០ហ្នឹងមីងទៅដល់ជងទន់ហ្នឹងតែម្តង?

សៀនៈ អត់ទេ ទៅដល់ទន់ដង់ឆ្នាំ៨០ប៉ុន្មាន ៨៥ឆ្ងន់ទន្លេ កាលហ្នឹងឡើងទៅប៉ុន្មានទេ ៨៣-៨៤ហ្នឹង បែបកាលហ្នឹង ខ្ញុំវាភ្លេចហើយណា ។

ប៊ុនថន: ចឹងឆ្នាំ៨០-៨១-៨២ មីងនៅណា?

សៀនៈ ឆ្នាំ៨១-៨២ ខ្ញុំនៅទន្លេល្ពៅ កាលមិនទាន់រត់ដល់វៀតណាមដេញមកហ្នឹងរហូតមកខ្ញុំនៅទន្លេល្ពៅហ្នឹងតើ ៨១-៨២ហ្នឹងទន្លេល្ពៅ ឆ្នាំ៨៣-៨៤យួនបុកមកបានរត់មកដីថៃ ។

ប៊ុនថន: នៅមុំបីហ្នឹង?

សៀនៈ ចាស!មុំបីហ្នឹង ។

ប៊ុនថន: នៅហ្នឹងគេហៅ១០០១?

សៀនៈ ចាស!១០០១ តែភូមិខ្ញុំគេដាក់ភូមិប្រជាជនគេហៅភូមិទន្លេល្ពៅ ។

ប៊ុនថន: ចឹងដល់ឆ្នាំ៨៤វៀតណាមវាយខ្លាំងបានមីងរត់មកនៅដងទង់ចង្អក?

សៀនៈ ចាស!រត់មកនៅដងទង់ រត់ប៉ុន្មានកន្លែងនោះ ។

ប៊ុនថន: កាលនៅទន្លេល្ពៅហ្នឹងគេឲ្យមីងធ្វើអីពេលហ្នឹង គេមានបែងចែកកងទេ?

សៀនៈ បែងចែកគេចាត់តាំងបែងចែកជាកង ។

ប៊ុនថន: មីងនៅក្នុងកងណាដែលមីង?

សៀនៈ កងភ្លេចហើយ ។

ប៊ុនថន: មីងនៅជាទ័ពឬក៏ស្អីគេ?

សៀនៈ គេរៀបចាត់តាំងនៅក្នុងភូមិជាប់ៗគ្នាជាកងៗ គេរៀបជាកងយើងមានកូនមានចៅ ។

ប៊ុនថន: តែមីងនៅក្នុងក្របខ័ណ្ឌកងទ័ពឬជាប្រជាជន?

សៀនៈ រត់មកទាំងប្តីទាំងប្រពន្ធចឹងគេចាត់តាំងឲ្យនៅក្នុងជួរប្រជាជន ។

ប៊ុនថន: គេរៀបហ្នឹងគេឲ្យមីងធ្វើអី ពេលនៅទន្លេល្ពៅ?

សៀនៈ អត់មានធ្វើអីទេ គេមានដាំស្លដាំអីហូប អត់មានធ្វើស្រែចម្ការគេបើកអង្ករឲ្យហូប ។

ប៊ុនថន: បានរបបដែរ?

សៀនៈ ចាស!ប្រជាជនគេបើកឲ្យហូប ។

ប៊ុនថន: ហូបគ្រប់គ្រាន់ទេមីង?

សៀនៈ អត់អីទេ បើកឲ្យហូបគ្រប់គ្រាន់ ព្រោះអីយើងសត្វចិញ្ចឹមជ្រូកអីយើងកាប់ចែកគ្នាហូបអត់មានពីណាលក់ឲ្យពីណាទេ ចែកគ្នាហូបទៅ ។

ប៊ុនថន: អត់មានពីណាហាមឃាត់អីទេ ចង់កាប់ពេលណាក៏បាន?

សៀនៈ  អត់មានទេ កាប់ពេលណាក៏បានដែរ ក្នុងន័យថាយើងសាមគ្គីគ្នា យើងកាប់ចែកគ្នាហូបទៅជ្រូក មាន់ ទា យើងចិញ្ចឹមហូបខ្លួនឯង អត់មានខុះអីហូបទេ មិនសូវកំសត់ដូចកាលនៅក្នុងព្រៃទេ ។

ប៊ុនថនៈ  ចឹងគ្រួសារមីងគាត់ឡើងទៅវាយប្តីមួយគាត់នៅជាមួយមីង នៅទន្លេល្ពៅហ្នឹង ប្តីមីង?

សៀនៈ  រត់មកបែកគ្នាហ្នឹងណា ។

ប៊ុនថនៈ  បែកគ្នាត្រឹមណា?

សៀនៈ  បែកគ្នា ។

ប៊ុនថនៈ  ពេលមកដល់ណា?

សៀនៈ  យួនវាយបែកគ្នាបាត់រហូតមិនដឹងជាគាត់ទៅណាទៅណី ។

ប៊ុនថនៈ  វាយបែកទន្លេល្ពៅហ្នឹង?

សៀនៈ  ហ្នឹងហើយមួយសារហ្នឹង វាយបែកទន្លេល្ពៅរត់មករតនគីរីចឹងមក មកតាមផ្លូវយួនវាយមិនដឹងជាគាត់ទៅណាទៅណីបែករហូតខ្ញុំនៅជាមួយកូន មានបាននៅស្រួលណារត់បែកគ្នារហូត ។

ប៊ុនថនៈ  មីងនៅហ្នឹងបានបួនឆ្នាំមីង ៨០-៨១-៨២-៨៣ ដល់៨៤បានមកដងទង់វិញ?

សៀនៈ  មិនដឹងជា៨០ប៉ុន្មានទេ ។

ប៊ុនថនៈ  ចឹងមីងមានដែលទទួលដំណឹងពីគាត់ទេ ក្រោយមកគ្រួសារមីង?

សៀនៈ  ដំណឹងថានៅនេះដំណឹងថានៅនោះ មិនដឹងជានៅណាពិតប្រាកដ មិនដឹងជាគាត់ទៅណា រហូតបាត់ជ្រាបរហូតសួរដំណឹង ដឹងថានៅណា ខ្ញុំមិនដឹងជាទៅរកអីណាខ្ជិល ។

ប៊ុនថនៈ  ដល់ក្រោយមីងមានគ្រួសារទៀត?

សៀនៈ  ចាស ។

ប៊ុនថនៈ  គ្រួសាក្រោយយកឆ្នាំណា?

សៀនៈ  កាលហ្នឹងយកដឹងថាឆ្នាំណាទេ ឆ្នាំប៉ុន្មានទេខ្ញុំចង់ភ្លេចអស់ហើយ ។

ប៊ុនថនៈ  ពេលនៅជំរំហ្នឹងឬក៏ឡើងមកនៅនេះហើយ?

សៀនៈ  ឡើងមកនេះខ្ញុំបាននៅជាមួយគ្នាយកនៅជាប្រជាជន ។

ប៊ុនថនៈ  យកនៅជំរំឬមួយយកនៅណា?

សៀនៈ  មកដល់នេះហើយហ្នឹង ដល់ជំរំអូរគ្រាវ គាត់ប្រជាជន ។

ប៊ុនថនៈ  មីងរស់នៅដងទង់ហ្នឹងបានប្រហែលជាប៉ុន្មានឆ្នាំ មីងមានដូរទៅណាទៀតទេ?

សៀនៈ  ដូរតើ ។

ប៊ុនថនៈ  ទៅណា?

សៀន៖ ដល់ហើយរត់មកដីខ្មែរយើងវិញ ។

ប៊ុនថន៖ ឆ្នាំណាមីងរត់មកដីខ្មែរ?

សៀន៖ មកដីខ្មែរឆ្នាំ៨០ប៉ុន្មានទេ ។

ប៊ុនថន៖ មុនអ៊ុនគាត់អីមីង មកខាងដីខ្មែរ?

សៀន៖ មុនអីទេ មិនមុនទេ ទេមកមុនអីមកដីខ្មែរហ្នឹង មកដើងភ្នំដងរែកហ្នឹង ហ្នឹងហើយមកមុន ។

ប៊ុនថន៖ ប្រហែលជាឆ្នាំ៨០ប៉ុន្មាន?

សៀន៖ អ៊ុនកាត់កើតឆ្នាំប៉ុន្មានឆ្នាំ៨៣អី អ៊ុនគាត់ឆ្នាំ៩៣ ។

ប៊ុនថន៖ ៩៣មីងមក?

សៀន៖ ចាស!ខ្ញុំមកមុនហ្នឹង៩០ មើល៩៣អ៊ុនគាត់មក មុនអ៊ុនគាត់មកខ្ញុំចុះមកនេះហើយ ខ្ញុំចុះមកនៅដីខ្មែរហើយហ្នឹង៩៣ កាលហ្នឹងខ្ញុំមកតាំងពី៩១-៩២ហ្នឹងឯង គេឲ្យប្រជាជនចុះមកនៅដីខ្មែរវិញ គេដឹកឲ្យមកនៅដីខ្មែរ ។

ប៊ុនថន៖ មកនៅដំបូងនៅម្ដុំណា?

សៀន៖ នៅច្រើនកន្លែងណាស់ ខ្ញុំនៅច្រើនកន្លែងម្ដុំអូរជីកហ្នឹង មកចឹងមកនៅនេះ យួនដេញរត់ទៅវិញទៅចឹងទៅ រត់ទៅវិញចឹង ពេលយួនទៅវិញគេឲ្យមកនៅនេះវិញ ក្រោយសមាហរណ៍កម្មក៏មកនៅនេះចប់ ដល់ស្រុកគេស្រួលគ្នាហើយ វាពិបាកណាស់នៅច្រើនកន្លែងពេករៀបរាប់មិនអស់ទេ ។

ប៊ុនថន៖ បាទ ។

សៀន៖ មានចាំខ្វះអីខ្វះ ។

ប៊ុនថន៖ ចឹងនៅភូមិនេះកើតក្រោយសមាហរណ៍កម្ម?

សៀន៖ ក្រោយសមាហរណ៍កម្មយើងចុះមកនៅនេះហើយបានមានសមាហរណ៍កម្ម ចុះមកនេះហើយតំបន់ប្រទាញប្រទង់ជាមួយខ្មែរក្រហមនិងទាហានខាងក្នុងនោះណាស់ ហ្នឹងហើយខ្ញុំមកនៅនេះស្រុកគេស្រួលគ្នាហើយ កាលហ្នឹងនៅមានលួចឆ្មក់អីដែលកាលហ្នឹង ដល់ហើយចឹងក៏សមាហរណ៍កម្មគេលែង គេផ្សះផ្សារគ្នាហើយពួកខ្ញុំចុះមកនៅនេះដាប់ ធ្វើសមាហរណ៍កម្មពួកខ្ញុំចុះមកនេះធ្វើខ្ទមប្រក់ដំបូលខ្ទមតូចៗហ្នឹង ។

ប៊ុនថន៖ ចឹងមីងមកដល់ហ្នឹងមុនសមាហរណ៍កម្មទៀតមែនទេ ភូមិនេះ?

សៀន៖ មុនហើយមកដល់ហើយបានមានសមាហរណ៍កម្ម ។

ប៊ុនថន៖ ភូមិហ្នឹងដំបូងគេដាក់ភូមិអីវិញ?

សៀន៖ ភូមិទួលប្រាសាទហ្នឹងតែម្ដង ។

ប៊ុនថនៈ ឃុំ?

សៀនៈ ឃុំទំនប់ដាច់ កាលពីដំបូងបង្អស់គេដាក់ស្រុកអន្លង់វែង ឥឡូវគេដាក់ស្រុកត្រពាំងប្រាសាទ ។

ប៊ុនថនៈ ចឹងដំបូងអន្លង់វែង?

សៀនៈ ចាស!ពីដើមអន្លង់វែងឥឡូវត្រពាំងប្រាសាទ ។

ប៊ុនថនៈ ចឹងដំបូងមានវត្តមានអីទេ?

សៀនៈ អត់មានទេ ដំបូងបង្អស់ទើបកសាងក្រោយទេ ។

ប៊ុនថនៈ កសាងក្រោយឆ្នាំប៉ុន្មានមីង?

សៀនៈ កសាងសមាហរណ៍កម្មហើយនេះ បាទប៉ុន្មានឆ្នាំទេ គេកសាងហ្នឹង ។

ប៊ុនថនៈ វត្តនៅទំនប់ដាច់ហ្នឹង?

សៀនៈ ចាស!មិនដឹងជាឆ្នាំប៉ុន្មានទេ វាមិនសូវចាំដែរ ។

ប៊ុនថនៈ ពីមុនមកអត់មានទេ?

សៀនៈ អត់មានវត្តទេ ។

ប៊ុនថនៈ នៅខាងថៃក៏អត់មានដែរ?

សៀនៈ អត់មានទេ ចុះយើងដើរនៅតាមព្រំដែន មិនទាន់មានវត្តមានលោកអី ។

ប៊ុនថនៈ ចឹងទើបមានវត្តហើយបានមីងបានទៅ?

សៀនៈ ចាស!បានទៅវត្តបានទៅអីហ្នឹង ។

ប៊ុនថនៈ ពីមុនមកអត់ដែលទេ?

សៀនៈ អត់ដែលទេ ។

ប៊ុនថនៈ ចឹងមីងរាល់ថ្ងៃមានកូនប៉ុន្មាននាក់មីង?

សៀនៈ នៅនិងខ្លួនរាល់ថ្ងៃហ្នឹងមានបួននាក់ ។

ប៊ុនថនៈ មីងប្រកបមុខរបរអីដែរ?

សៀនៈ នៅរាល់ថ្ងៃធ្វើស្រែចម្ការ ។

ប៊ុនថនៈ កូនៗមីងកើតទាន់ជំនាន់ហ្នឹងដែរ?

សៀនៈ កើតទាន់ជំនាន់ហ្នឹងតែវាស្លាប់ហើយ បើអ្នកនៅហ្នឹងកើតនៅជំរំ ។

ប៊ុនថនៈ មានដឹងរឿងច្រើនទេ មីងមានដែលនិយាយប្រាប់រឿងមីងអីចឹង ។

សៀនៈ ដែលមាននិយាយប្រាប់គេ តែវាមិនជឿទេ ។

ប៊ុនថនៈ ម៉េចចឹង?

សៀនៈ  វាមិនជឿ យើងប្រាប់ថានៅនេះរត់គ្រាប់រត់អី ទាល់យើងនិយាយបញ្ជាក់បានវាជឿដែរ វាកើតចំស្រុកស្រួលនេះហើយក៏មាន តែវាមិនសូវដឹងទេ អាបងវាកើតមុននោះវាដឹង រត់យួនវាអី យួនដេញបាញ់វាដឹង ដល់កូនក្រោយមួយពៅនេះវាអត់ដឹងទេ វាមិនជឿ វាអត់ដឹងដែរ វាមានដឹងថាយើងលំបាកអី វាមិនសូវជឿទេ យើងប្រាប់បញ្ជាក់និយាយអីបានជឿ អាមួយទាន់កើតនៅរតនគិរីអាហ្នឹងវាស្គាប់បាត់ហើយ អាក្រោយនេះកើតមកនៅជំរំអី អាហ្នឹងពិបាកណាស់ ។

ប៊ុនថនៈ  អ្នកជិតខាងមីងហ្នឹងសុទ្ធតែអ្នកមកពីក្នុងដែរ?

សៀនៈ  ចាស!សុទ្ធអ្នកចេញមកជំនាន់ហ្នឹងដូចគ្នាហ្នឹង ជួនណាក្មេងវាកើតនៅនេះចឹងវាមានប្តីមានកូនមានចៅទៅណាស់ បើម៉ែឪមកសុទ្ធតែនៅអីស្រុកទេ យើងចាស់ៗនោះ និយាយរួមអ្នកនៅនេះដុះឫសក្នុងភូមិតែម្តងអត់មានទេ ។

ប៊ុនថនៈ  ចឹងយើងរាប់អានគ្នាដូចបងប្អូន?

សៀនៈ  ចាស!ដូចបងប្អូនយើងបង្កើតអ្នកជិតខាង បងប្អូនមានតែនៅស្រុកនោះ នៅនេះមានណាខ្លះគេយកបងប្អូនគេមកទៅ ខ្លះគេមិនយកមកទៅបងប្អូនកូនក្មួយសុទ្ធតែអ្នកធ្វើការ ។

ប៊ុនថនៈ  ខ្ញុំដូចជាអស់អីសួរមីងហើយ តើមីងមានអីចង់បន្ថែមទៀតទេ?

សៀនៈ  ចាស!អត់មានទេ អត់មានស្អីបន្ថែមទេ ។

ប៊ុនថនៈ  ចឹងអរគុណមីងច្រើន ។

សៀនៈ  ចាស ។

**ចប់**